# ព្រះរាជក្រឹត្យ នស/រកត/០២០០/០៣៩

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ រាជហរិវង្ស
## ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម
## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
## ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ .-** បង្កើតគណៈគ្រូពេទ្យមួយដើម្បីប្រមូលផ្តុំគ្រូពេទ្យទាំងអស់ដែលមាននីតិសម្បទាគ្រប់គ្រាន់អាចប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ នៅព្រះរាជាណាចក្រកម្ពុជា ។

ពាក្យថាគ្រូពេទ្យក្នុងព្រះរាជក្រឹត្យនេះ គឺនីតិជនដែលមានសញ្ញាប័ត្រវេជ្ជសាស្ត្រ ទទួលស្គាល់ដោយក្រសួងសុខាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។

គ្រូពេទ្យទាំងអស់ដែលប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ ត្រូវតែសុំចុះឈ្មោះនៅក្នុងបញ្ជីគណៈគ្រូពេទ្យ ។

## ផ្នែកទី២
## បេសកកម្មរបស់គណៈគ្រូពេទ្យ

**មាត្រា២ .-** គណៈគ្រូពេទ្យ ត្រូវឃ្លាំមើលការប្រព្រឹត្តិទៅនៃបញ្ហាគោលការណ៍សីលធម៌ ភាពសុច្ចរិត យុត្តិធម៌ និងភក្តីភាពចាំបាច់ក្នុងការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រអោយបានគង់វង្ស និងមានប្រសិទ្ធភាព ។

គណៈគ្រូពេទ្យ ត្រូវឃ្លាំមើលការប្រតិបត្តិសមាជិករបស់ខ្លួនទាំងអស់ចំពោះ ករណីយកិច្ចវិជ្ជាជីវៈ ព្រមទាំងបទបញ្ញត្តិទាំងឡាយដែលមានចែងនៅក្នុងក្រមសីលធម៌គ្រូពេទ្យ ។

គណៈគ្រូពេទ្យ ធានាការពារកិត្តិយស និងឥស្សរភាព របស់វិជ្ជាជីវៈវេជ្ជសាស្ត្រ ។

គណៈគ្រូពេទ្យ បំពេញភារកិច្ចរបស់ខ្លួនតាមរយៈក្រុមប្រឹក្សា គណៈគ្រូពេទ្យខេត្ត-ក្រុង ក្រុមប្រឹក្សាគណៈគ្រូពេទ្យភូមិភាគ និងក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិ ។

## ជំពូកទី ៣

## តួនាទី សីលធម៌

មាត្រា៣ .- គណៈគ្រូពេទ្យ មានបន្ទុកប្រមូលក្រមសីលធម៌គ្រូពេទ្យហើយណែនាំតាមលក្ខណៈចាំបាច់ នៃវិជ្ជាជីវៈក្នុងការវិវត្តខ្លាប់ខ្លួន ខាងបច្ចេកទេសសេដ្ឋកិច្ច និងសង្គមកិច្ច ដែលត្រូវធ្វើអោយវិវត្តល្អក្នុងផលប្រយោជន៍របស់អ្នកជំងឺ ។

គណៈគ្រូពេទ្យ តាមឃ្លាំមើលរាល់ការប្រតិបត្តិកិច្ចការ និងសេចក្តីគោរពប្រណិបត្តិ ។

គណៈគ្រូពេទ្យជាអង្គការស្វយ័ត ។ ការតំណាងរ ការផ្តល់ផ្តង់ប្រាក់កាសជាម្ចាស់ការខ្លួនឯង ធានាឥស្សរភាពការពារផលប្រយោជន៍សីលធម៌ វិជ្ជាជីវៈ ។

## ជំពូកទី ៤

## តួនាទី គ្រប់គ្រងរដ្ឋបាល

មាត្រា៤ .- គណៈគ្រូពេទ្យ ចាត់ចែងអំណាចដោយអនុលោមតាមបទបញ្ញា ។

គណៈគ្រូពេទ្យ ត្រូវរៀបចំធ្វើ និងថែរក្សាទុកជាប្រចាំថ្ងៃ នូវបញ្ជីរាយនាមគ្រូពេទ្យ ដែលបានចុះឈ្មោះបំពេញលក្ខខណ្ឌច្បាប់ និងសីលធម៌ចាំបាច់ ។

កាតព្វកិច្ច នៃការចុះឈ្មោះក្នុងបញ្ជីរាយនាមគ្រូពេទ្យ គឺដើម្បីបំពេញការថែទាំ ព្យាបាលជំងឺ (មាត្រា១០ នៃច្បាប់ស្តីពីការគ្រប់គ្រងការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ) លើកលែងតែគ្រូពេទ្យយោធាសកម្មដែលមិនអនុញ្ញាតអោយឈរឈ្មោះបើកមន្ទីរសំរាកព្យាបាលឯកជនទេ ។

## ជំពូកទី ៥

## តួនាទី សំរេចសេចក្តីតាមបែបតុលាការ

មាត្រា៥ .- គ្រូពេទ្យណាម្នាក់ បានប្រព្រឹត្តខុសឆ្គងលើប្រការណាមួយនៃមុខវិជ្ជាជីវៈរបស់ខ្លួន ធ្ងន់ធ្ងរជាងកំហុសឆ្គងដែលមានចែងក្នុងមាត្រា២៦ នៃព្រះរាជក្រឹត្យនេះ តុលាការមានសិទ្ធិធ្វើការជំនុំជំរះកំហុសឆ្គងនិងការដាក់វិន័យជាយថាហេតុតាមច្បាប់ជាធរមាន ។

## ផ្នែកទី ៦

## តួនាទី ពិគ្រោះផ្តល់យោបល់

មាត្រា៦ .- គណៈគ្រូពេទ្យ ត្រូវបានកោះហៅផ្តល់យោបល់លើគំរោង នៃបទបញ្ញត្តិ : ក្រឹត្យ ឬ ច្បាប់ដែលដាក់អោយ ពិនិត្យដោយអំណាច នីតិប្រតិបត្តិ ។

## ផ្នែកទី ៧

## តួនាទី ជួយសង្គ្រោះគ្នាទៅវិញទៅមក

មាត្រា៧ .- ការជួយសង្គ្រោះគ្នាទៅវិញទៅមកនេះមានបច្ច័យដល់គ្រូពេទ្យ និងគ្រួសាររបស់គេ ។

ការជួយសង្គ្រោះគ្នាបានរៀបចំតាម បែបបទដូចតទៅ :

ក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិ ត្រូវមានក្នុងថវិការបស់ខ្លួន ប្រាក់បំរុងសំរាប់ជួយសង្គ្រោះគ្នាទៅវិញទៅមក ដើម្បីអនុញ្ញាតអោយប្រើប្រាស់ប្រាក់បំរុងជាជំនួយផ្សេងៗ ក្នុងករណីសមរម្យដល់គ្រួសារពេទ្យដែលត្រូវរង ទុក្ខលំបាក ។

ក្រុមប្រឹក្សានេះត្រូវមានគណៈកម្មការជាតិមួយ ជួយសង្គ្រោះគ្នាទៅវិញទៅមក ដែលមានតំណាងសមាគម គ្រូពេទ្យកម្ពុជា ជាសមាជិក ។

គណៈកម្មការនេះ ចាត់ចែងអោយមានធនធានប្រចាំឆ្នាំ ដែលកាត់យកខ្លះពីប្រាក់វិភាគទានពីគ្រូពេទ្យ ម្នាក់ៗដែលចុះឈ្មោះក្នុងគណៈគ្រូពេទ្យ ។

# ជំពូកទី ២

# រចនាសម្ព័ន្ធ

## ផ្នែកទី ១

## ក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត-ក្រុង

មាត្រា៨ .- ក្រុមប្រឹក្សាគណៈគ្រូពេទ្យ ខេត្ត-ក្រុង ដែលសរសេរកាត់ថា “ក.គ.ខ” ត្រូវបង្កើតនៅតាមខេត្ត-ក្រុង នីមួយៗ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ចំពោះខេត្ត-ក្រុង ដែលមានចំនួនគ្រូពេទ្យ តិចជាង២០នាក់ត្រូវបញ្ចូលទៅខេត្តដែលនៅជិតជាងគេ ដើម្បី បង្កើតក្រុមប្រឹក្សាគណៈគ្រូពេទ្យ ។

មាត្រា៩ .- ក.គ.ខ មានសមាជិកពេញសិទ្ធិចំនួន៥រូប និងសមាជិកជំនួយចំនួន ៥រូប ក្នុងករណីចំនួនគ្រូពេទ្យដែល បានចុះឈ្មោះ ត្រូវក្នុងបញ្ជីមានមិនលើសពី ១០០នាក់ ។

ចំនួននេះនឹងឡើងដល់១១-១៥-១៩ ឬ ២១រូប ប្រសិនចំនួនគ្រូពេទ្យនៅក្នុងបញ្ជីមានលើសពី១០០នាក់- ៥០០នាក់-១០០០នាក់ ឬ ២០០០នាក់ ។

មាត្រា ១០ .- ក.គ.ខ ត្រូវបានបោះឆ្នោតជ្រើសរើសនៅក្នុងអង្គមហាសន្និបាត ដោយពួកគ្រូពេទ្យដែលបានចុះឈ្មោះនៅក្នុងបញ្ជីរបស់ ក.គ.ខ សំរាប់រយៈពេល៦ឆ្នាំ ។

សមាជិកចប់អាណត្តិអាចឈរឈ្មោះអោយគេបោះឆ្នោតជ្រើសរើសជាថ្មីសាឡើងវិញបាន ។

ក្រុមប្រឹក្សាធ្វើការបោះឆ្នោតជ្រើសរើសប្រធាន និងការិយាល័យរបស់ខ្លួននៅក្នុងរយៈពេល២ឆ្នាំម្តង ក្រោយពីបានធ្វើការផ្លាស់ប្តូរចំនួន ១/៣ នៃសមាជិករបស់ក្រុមប្រឹក្សា ។

ការិយាល័យរបស់ ក.គ.ខ រួមមាន : ប្រធានក្រុមប្រឹក្សាមួយរូប អនុប្រធានមួយរូប ឬច្រើន អគ្គលេខាធិការមួយរូប អគ្គលេខាធិការរងមួយរូប ឬ ច្រើន ហេរញ្ញិកមួយរូប និងហេរញ្ញិករងមួយរូប ។

មាត្រា ១១ .- ក.គ.ខ បំពេញការងារនៅក្នុងក្របខ័ណ្ឌខេត្ត-ក្រុង របស់ខ្លួន និងក្រោមការត្រួតពិនិត្យរបស់គណៈគ្រូពេទ្យជាតិចំពោះសមត្ថកិច្ចទូទៅទាំងឡាយ ដែលមានចែងនៅក្នុងមាត្រា២ នៃព្រះរាជក្រឹត្យនេះ ។ ក.គ.ខ. សំរេចអោយកត់ក្នុងការចុះឈ្មោះគ្រូពេទ្យដែលបានបំពេញល័ក្ខខ័ណ្ឌតាមមាត្រា ៣.៦ នៃច្បាប់ស្តីពីការគ្រប់គ្រងការប្រកបវិជ្ជាជីវៈឯកជនផ្នែកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រជំនួយវេជ្ជសាស្ត្រនៅក្នុងបញ្ជីរបស់គណៈគ្រូពេទ្យ ។ ក.គ.ខ មិនប្រកាន់ពូជ ជំនឿ សាសនា និន្នាការនយោបាយ ឋានៈសង្គម ធនធាន ឬ ស្ថានភាពឯទៀតរបស់សមាជិកខ្លួនឡើយ ។

មាត្រា ១២ .- ក.គ.ខ ពុំមានអំណាចជាវិន័យទេ ។ បើមានពាក្យបណ្តឹងចំពោះគ្រូពេទ្យ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួន ក.គ.ខ. ត្រូវបញ្ជូនបណ្តឹងនោះទៅក្រុមប្រឹក្សាគណៈគ្រូពេទ្យភូមិភាគ ដោយបញ្ជាក់ហេតុផលច្បាស់លាស់ ។

មាត្រា ១៣ .- ប្រធានតំណាងអោយ ក.គ.ខ នៅក្នុងគ្រប់សកម្មភាពស៊ីវិល ។

មាត្រា ១៤ .- ការប្រជុំនៃក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត-ក្រុង នឹងមិនធ្វើជាសាធារណៈឡើយ ។

កាលណាមានសំឡេងស្មើគ្នា សំឡេងរបស់ប្រធានមានឥទ្ធិពលសំរេច ។

ប្រធានមន្ទីរសុខាភិបាលខេត្ត-ក្រុង ត្រូវបានអញ្ជើញចូលរួមក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា គ្រាន់តែមានសំឡេងពិគ្រោះយោបល់ ។

ក.ខ.គ. អាចអញ្ជើញទីប្រឹក្សាច្បាប់មួយរូបចូលរួមក្នុងអង្គប្រជុំ ។

មាត្រា ១៥ .- គ្រូពេទ្យប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រនៅតាមបណ្តាខេត្ត-ក្រុង ត្រូវដាក់ពាក្យសុំចុះឈ្មោះនៅក្នុងបញ្ជីដែលកាន់កាប់ជាប្រចាំ ដោយក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត-ក្រុងពាក់ព័ន្ធ ។

អាចចុះឈ្មោះនៅក្នុងបញ្ជីគណៈគ្រូពេទ្យ តែចំពោះគ្រូពេទ្យដែលមានសញ្ញាប័ត្រវេជ្ជសាស្ត្រទទួលស្គាល់ដោយក្រសួងសុខាភិបាលក្នុងការប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រ និងបានបំពេញល័ក្ខខ័ណ្ឌច្បាប់ និងល័ក្ខខ័ណ្ឌសីលធម៌ ដែលបានកំណត់ ។

គ្រូពេទ្យអាចចុះឈ្មោះបានតែនៅក្នុងបញ្ជីនៃខេត្ត-ក្រុង ដែលជាកន្លែងប្រកបវិជ្ជាជីវៈរបស់ខ្លួនតែប៉ុណ្ណោះ ។

**មាត្រា ១៦ .-** ក.គ.ខ ត្រូវសម្រេចលើការសុំចុះឈ្មោះក្នុងរយៈពេលយ៉ាងយូរមួយខែ ដោយគិតចាប់តាំងពីថ្ងៃទទួលពាក្យដែលមានឯកសារគ្រប់គ្រាន់ ។

ក្នុងរយៈពេលមួយសប្តាហ៍យ៉ាងយូរក្រោយការសម្រេច ក្រុមប្រឹក្សាត្រូវជូនដំណឹងតាមលិខិតអនុសាសន៍ទៅគ្រូពេទ្យសាមី ។ បើមានការបដិសេធ សេចក្តីសម្រេចត្រូវតែមានមូលហេតុច្បាស់លាស់ ។

ការអនុញ្ញាតឲ្យចុះឈ្មោះនៅក្នុងបញ្ជីគណៈគ្រូពេទ្យខេត្ត-ក្រុងនីមួយៗ ត្រូវតែជូនដំណឹងយ៉ាងឆាប់រហ័សទៅអាជ្ញាខេត្ត-ក្រុង ទៅព្រះរាជអាជ្ញានៃខេត្ត-ក្រុងពាក់ព័ន្ធ និងទៅក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិ ។

**មាត្រា ១៧ .-** ក្រោយពីបានការអនុញ្ញាតឲ្យចុះឈ្មោះនៅក្នុងបញ្ជីគណៈគ្រូពេទ្យខេត្ត-ក្រុង ដែលខ្លួនរស់នៅហើយ គ្រូពេទ្យអាចប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រនៅខេត្ត-ក្រុងដែលខ្លួនបានចុះឈ្មោះប៉ុណ្ណោះ ។

ក្នុងករណីមានការផ្លាស់ប្តូរពីស្ថានវិជ្ជាជីវៈទៅក្រៅខេត្ត-ក្រុងដែលខ្លួនបានសុំចុះឈ្មោះ គ្រូពេទ្យត្រូវជូនដំណឹងទៅក្រុមប្រឹក្សាចាស់ និងត្រូវធ្វើពាក្យសុំចុះឈ្មោះសាជាថ្មី ទៅក្រុមប្រឹក្សាខេត្ត-ក្រុងដែលខ្លួនទៅរស់នៅ ។

**មាត្រា ១៨ .-** ក្រុមប្រឹក្សាគណៈគ្រូពេទ្យខេត្ត-ក្រុង ត្រូវទទួលការប្តឹងតវ៉ាទុកអំពីក្រុមប្រឹក្សាជាតិ អំពីសមាគមគ្រូពេទ្យ អំពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល អំពីប្រធានមន្ទីរសុខាភិបាលខេត្ត-ក្រុង អំពីព្រះរាជអាជ្ញា ឬ អំពីគ្រូពេទ្យណាម្នាក់ដែលបានចុះឈ្មោះនៅក្នុងបញ្ជីគណៈគ្រូពេទ្យ រួចហើយធ្វើរបាយការណ៍ ផ្ញើជូនគណៈគ្រូពេទ្យជាតិ ។

## ផ្នែកទី ៣

## ក្រុមប្រឹក្សាគណៈគ្រូពេទ្យភូមិភាគ
## (ឬ ក្រុមប្រឹក្សាវិន័យ វិជ្ជាជីវៈ ថ្នាក់បឋម)

**មាត្រា ១៩ .-** ក្រុមប្រឹក្សាគណៈគ្រូពេទ្យភូមិភាគសរសេរកាត់ថា " ក.គ.ភ." (ឬក្រុមប្រឹក្សាវិន័យវិជ្ជាជីវៈថ្នាក់បឋម) មានសមាជិកពេញសិទ្ធិចំនួន ៩រូប និងសមាជិកជំនួសចំនួន ៩រូប បោះឆ្នោតជ្រើសរើសក្នុងចំណោម ក.គ.ខ. ក្នុងភូមិភាគ ។ ក.គ.ខ. នីមួយៗត្រូវជ្រើសរើសតំណាងរបស់ខ្លួនឲ្យបានយ៉ាងតិចមួយរូបពេញសិទ្ធ និងមួយរូបជំនួស ។ ចំនួនអាសនៈដែលនៅសល់ត្រូវបែងចែកទៅខេត្ត-ក្រុង ធៀបទៅលើចំនួនគ្រូពេទ្យដែលបានចុះឈ្មោះនៅក្នុងបញ្ជីតាមក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិ ។

សមាជិកក្រុមប្រឹក្សាភូមិភាគ ត្រូវបានបោះឆ្នោតជ្រើសរើសសម្រាប់រយៈពេល ៦ឆ្នាំ ។ សមាជិកចប់អាណត្តិអាចឈរឈ្មោះឲ្យគេបោះឆ្នោតជ្រើសរើសជាថ្មីឡើងវិញបាន ។ ក្រុមប្រឹក្សាធ្វើការបោះឆ្នោតជ្រើសរើសប្រធាន និងការិយាល័យរបស់ខ្លួននៅក្នុងរយៈពេល ២ឆ្នាំម្តង ក្រោយពីបានធ្វើការផ្លាស់ប្តូរចំនួន ១/៣ នៃសមាជិកក្រុមប្រឹក្សា ។ សមាជិកជំនួសត្រូវចូលជំនួសសមាជិកពេញសិទ្ធនៅពេលដែលសមាជិកនេះអវត្តមានដោយមូលហេតុអ្វីក៏ដោយ ។

មាត្រា២០ .- ប្រធាន ក.គ.ខ. ប្រធាន ក.គ.ភ. និងអគ្គលេខាធិការ នៃក្រុមប្រឹក្សាទាំងនេះ មិនអាចកាន់មុខងារត្រួតគ្នាបានឡើយ ។

មាត្រា២១ .- អង្គប្រជុំនៃ ក.គ.ខ. ត្រូវបានចូលរួម ក្នុងលក្ខណៈជាអនុប្រធាន និងជាអ្នកពិគ្រោះយោបល់ដោយ :

- ប្រធានមន្ទីរសុខាភិបាលខេត្ត-ក្រុង ដែលជាទីតាំងនៃក្រុមប្រឹក្សាភូមិភាគតំណាងអោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។
- ទីប្រឹក្សាច្បាប់មួយរូប តាត់តាំងដោយប្រធានតុលាការនៃខេត្ត-ក្រុងនោះ ។
- គ្រូពេទ្យការងារមួយរូប (បើមាន) តាត់តាំងដោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។
- នាយកសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រភូមិភាគ តាត់តាំងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

មាត្រា២២ .- នៅក្នុងក្របខ័ណ្ឌគណៈគ្រូពេទ្យ ក.គ.ភ. អនុវត្តការងាររបស់ខ្លួនតែទៅលើសមត្ថកិច្ចខាងវិន័យតែប៉ុណ្ណោះ ។

ក.គ.ភ.អាចទទួលពាក្យបណ្តឹងសារទុក្ខ ពី ក.គ.ជ. ពី ក.គ.ខ. ពីសមាគមគ្រូពេទ្យ ពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល ពីប្រធានមន្ទីរសុខាភិបាល ពីអាជ្ញាធរ ពីព្រះរាជអាជ្ញាខេត្ត-ក្រុង ឬ អំពីសាមីគ្រូពេទ្យដែលបានចុះឈ្មោះនៅក្នុងបញ្ជីគ្រូពេទ្យ ។

ក.គ.ខ. ត្រូវពិនិត្យសំរេចនៅក្នុងរយៈពេល៦ខែយ៉ាងយូរក្រោយបានទទួលពាក្យបណ្តឹង ។ បើមិនដូច្នេះទេ ក.គ.ជ. អាចបញ្ជូនពាក្យបណ្តឹងនេះទៅ ក.គ.ភ. ណាមួយផ្សេងដែលបានជ្រើសរើស ។

មាត្រា២៣ .- គ្រូពេទ្យដែលកំពុងបំរើការនៅក្នុងសេវាសាធារណៈ ហើយបានសុំចុះឈ្មោះនៅក្នុងបញ្ជីគណៈគ្រូពេទ្យ នឹងអាចអញ្ជើញមកបកស្រាយនៅចំពោះមុខ ក.គ.ភ. បាន ចំពោះសកម្មភាពក្នុងមុខងារសាធារណៈរបស់ខ្លួន តែតាមរយៈរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមរយៈប្រធានមន្ទីរសុខាភិបាលខេត្ត-ក្រុង ឬ តាមរយៈព្រះរាជអាជ្ញាតែប៉ុណ្ណោះ ។

មាត្រា២៤ .- ការដាក់ទោសវិន័យត្រូវធ្វើឡើងនៅចំពោះមុខគ្រូពេទ្យសាមី ។ គ្រូពេទ្យសាមីត្រូវតែមានអ្នកការពារដែលជាគ្រូពេទ្យ ឬ ជាមេធាវីទទួលស្គាល់ដោយច្បាប់ ។

មាត្រា២៥ .- ក្រុមប្រឹក្សាគណៈគ្រូពេទ្យភូមិភាគ ត្រូវមានបញ្ជីកត់ត្រា ការជំនុំជំរះកាត់សេចក្តី នៅក្រោយសវនាការនីមួយៗ ។ គេត្រូវធ្វើកំណត់ហេតុត្រឹមត្រូវដោយមានការបញ្ជាក់និងចុះហត្ថលេខាពីគ្រប់សមាជិកទាំងអស់នៃក្រុមប្រឹក្សា ព្រមទាំងហត្ថលេខារបស់សាមីជនដែលត្រូវគេចោទសួរនោះផង ។

មាត្រា២៦ .- ក.គ.ភ.ដោយមានការចូលរួមពីផ្នែកវិន័យ នៃ ក.គ.ជ. អាចដាក់វិន័យដូចខាងក្រោម :

១- ការព្រមាន

២- សេចក្តីបន្ទោសដោយកត់ទុកនៅក្នុងឯកសារផ្ទាល់ខ្លួន

៣- ហាមប្រកបវិជ្ជាជីវៈមួយរយៈពេលមិនលើសពីបីឆ្នាំ ឬ ជាអចិន្ត្រៃយ៍ក្នុងផ្នែកណាមួយ ឬជាទូទៅនៃមុខងារវេជ្ជសាស្ត្រដែលរដ្ឋទទួលស្គាល់

៤- ការលុបឈ្មោះចេញពីបញ្ជីគណៈគ្រូពេទ្យ ។

គ្រូពេទ្យដែលបានទទួលវិន័យ ត្រូវបាត់សមាជិកភាពនៅក្នុង ក.គ.ខ. ក.គ.ភ. ឬ ក.គ.ជ. ក្នុងរយៈពេលពី ១-៣ ឆ្នាំ ចំពោះវិន័យថ្នាក់ទី១ និងទី២ និងបាត់បង់ជាអចិន្ត្រៃយ៍ចំពោះវិន័យ ថ្នាក់ទី៣ និងទី៤ ។

គ្រូពេទ្យដែលត្រូវលុបឈ្មោះចេញពីក្នុងបញ្ជីមិនអាចសុំចុះឈ្មោះនៅកន្លែងណាផ្សេងទៀតបានឡើយ ។

សេចក្តីសម្រេចចុងក្រោយដែលបានលើកឡើង ត្រូវតែផ្សព្វផ្សាយទៅគ្រប់ ក.គ.ខ. ព្រមទាំងទៅ ក.គ.ជ.។

ការសម្រេចរបស់ ក.គ.ភ. ត្រូវតែមានហេតុផលច្បាស់លាស់ ។

**មាត្រា២៧ .-** ក្រោយបានទទួលការលុបឈ្មោះចេញពីបញ្ជី អស់រយៈកាលបីឆ្នាំយ៉ាងតិចមក គ្រូពេទ្យពាក់ព័ន្ធអាចទទួលការលើកលែងវិន័យអំពីក្រុមប្រឹក្សាគណៈគ្រូពេទ្យ ដែលបានដាក់វិន័យលើខ្លួន ។ ការសុំលើកលែងវិន័យនេះត្រូវធ្វើឡើងដោយគ្រូពេទ្យសាមី ។

កាលណាលិខិតស្នើសុំលើកលែងវិន័យនេះត្រូវបានបដិសេធ ក្រោយពីបានធ្វើការពិនិត្យពិចារណាស៊ីជំរៅមក ការស្នើសុំលើកលែងវិន័យសាជាថ្មីនឹងអាចធ្វើទៅបានតែក្នុងរយៈកាលមួយឆ្នាំទៅមុខទៀត ។

**មាត្រា២៨ .-** ការអនុវត្តនីវិន័យរបស់គណៈគ្រូពេទ្យមិនមែនជាឧបសគ្គរាំង រាល់ការអនុវត្តនីការដាក់វិន័យចំពោះអំពើខុសឆ្គងខាងក្រោមនេះឡើយ ។

១- ការចោទប្រកាន់ដែលរដ្ឋអំណាចសាធារណៈ ឬ ឯកជនអាចប្តឹងចំពោះតុលាការពីបទរដ្ឋប្បវេណី

២- សកម្មភាពស៊ីវិល ដើម្បីជួសជុលសងជំងឺចិត្ត ពីបទល្មើសថ្នាក់មជ្ឈិម

៣- ការដាក់វិន័យផ្នែករដ្ឋបាលនៅកន្លែងធ្វើការរបស់គ្រូពេទ្យ

៤- អំពើខុសឆ្គងដែលគ្រូពេទ្យបានប្រព្រឹត្តដោយរំលោភបំពាន ក្នុងការចូលរួមថែទាំវេជ្ជសាស្ត្រដែលបានគ្រោងនៅក្នុងច្បាប់សង្គម ។

ឧបសម្ព័ន្ធ :

- ភូមិភាគ ១ : រួមមានខេត្តកណ្តាល រាជធានីភ្នំពេញ ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង មានទីតាំងនៅរាជធានីភ្នំពេញ ។
- ភូមិភាគ ២ : មានខេត្តពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងក្រុងប៉ៃលិន មានទីតាំងនៅខេត្តបាត់ដំបង ។
- ភូមិភាគ ៣ : មានខេត្តតាកែវ កំពត កោះកុង ក្រុងព្រះសីហនុ និងក្រុងកែប មានទីតាំងនៅខេត្តកំពត។

- ភូមិភាគ ៤ : មានខេត្តស្ទឹងត្រែង រតនៈគិរី មណ្ឌលគិរី ក្រចេះ និងព្រះវិហារ មានទីតាំងនៅខេត្តស្ទឹងត្រែង ។
- ភូមិភាគ ៥ : មានខេត្តកំពង់ចាម កំពង់ធំ ព្រៃវែង និងស្វាយរៀង មានទីតាំងនៅខេត្តកំពង់ចាម ។

## ជំពូកទី ៤
## ក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិកម្ពុជា

មាត្រា ២៩ .- ក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិ សរសេរកាត់ថា " ក.គ.ជ." ត្រូវបានជ្រើសរើសដោយបោះឆ្នោត សំរាប់ ៦ឆ្នាំ ដែលមានដូចខាងក្រោម :

- តំណាងអោយខេត្ត-ក្រុងនីមួយៗ ចំនួន ១រូប តែងតាំងដោយប្រធានមន្ទីរសុខាភិបាលខេត្ត-ក្រុង ។
- តំណាងអោយរាជធានីភ្នំពេញ ចំនួន ២រូប តែងតាំងដោយប្រធានមន្ទីរសុខាភិបាលរាជធានីភ្នំពេញ ។
- តំណាងអោយអង្គភាពថ្នាក់កណ្តាលចំនួន ៥រូប តែងតាំងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។
- តំណាងអោយសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ចំនួន១រូប ជ្រើសរើសដោយសហភាគៈរបស់គេ

មាត្រា ៣០ .- ក.គ.ជ. ត្រូវធ្វើការជ្រើសរើសផ្លាស់ប្តូរសមាជិក ចំនួន ១/៣ ក្នុងរយៈពេល២ឆ្នាំម្តង ។ ក្រោយពីបានធ្វើការផ្លាស់ប្តូរសមាជិកចំនួន១/៣ម្តងៗ ក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិត្រូវធ្វើការជ្រើសរើសប្រធាន និងការិយាល័យរបស់ខ្លួនសំរាប់ ២ឆ្នាំ ។

ការិយាល័យរបស់ក្រុមប្រឹក្សាគណៈគ្រូពេទ្យជាតិ រួមមាន : ប្រធានក្រុមប្រឹក្សា១រូប អនុប្រធាន ចំនួន២រូប អគ្គលេខាធិការ១រូប អគ្គលេខាធិការរង១រូប ហេរញ្ញិក ១រូប និង ហេរញ្ញិករង ១រូប ។

ប្រធាន និងសមាជិក ក.គ.ជ.ដែលចេញពីតំណែងអាចឈរឈ្មោះអោយគេជ្រើសរើសសាជាថ្មីបាន ។

មាត្រា ៣១ .- ក.គ.ជ. មានជំនួយការជាគ្រូពេទ្យចំនួន២រូប តំណាងអោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល១រូប និង តំណាងអោយរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា១រូប ក្នុងឋានៈជាអនុប្រធាន និង មានសម្លេងពិគ្រោះយោបល់ ។

មាត្រា ៣២ .- ក.គ.ជ. ត្រូវមានផ្នែកវិន័យត្រូវមានសមាជិក ៧រូប ដឹកនាំដោយប្រធាន ១រូប ជ្រើសតាំងក្នុងចំណោមសមាជិក ៧រូបនេះ ។

មាត្រា ៣៣ .- បន្ទាប់ពីបានធ្វើការជ្រើសរើសផ្លាស់ប្តូរសមាជិកចំនួន១/៣របស់ខ្លួន ក.គ.ជ. ត្រូវធ្វើការបោះឆ្នោតជ្រើសរើសផ្នែកវិន័យសាជាថ្មី ។

មាត្រា ៣៤ .- ក.គ.ជ. បំពេញតួនាទីថ្នាក់ជាតិរបស់ខ្លួននៅក្នុងបេសកកម្មដែលមានចែងនៅក្នុងមាត្រា២ នៃព្រះរាជក្រឹត្យនេះ ។

ក.គ.ជ.ឃ្លាំមើលជាអាទិ៍ ការគោរពអនុវត្តតាមរបស់សមាជិកនៃគណៈគ្រូពេទ្យទាំងអស់ ចំពោះករណីយកិច្ចវិជ្ជាជីវៈ និងគោលការណ៍ទាំងឡាយដែលបានកំណត់នៅក្នុងក្រមសីលធម៌គ្រូពេទ្យ ។ ក.គ.ជ

សហការជាមួយ ក.គ.ខ. ធ្វើការសិក្សាដោះស្រាយនូវបញ្ហាស្មុគស្មាញទាំងឡាយ ដែលពាក់ព័ន្ធទៅនឹងប្រព្រឹត្តកម្មវិជ្ជាជីវៈរបស់គ្រូពេទ្យ ។

ក.គ.ជ បំពេញការងារនេះតាមរយៈផ្នែក និងគណៈកម្មការទាំងឡាយរបស់ខ្លួននឹងពិនិត្យសិក្សានូវបណ្ដាបញ្ហា ឬ ព័រោងការណ៍ទាំងឡាយដែលបានលើកឡើងដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬ ពីស្ថាប័នពាក់ព័ន្ធផ្សេងៗ ។

**មាត្រា ៣៥** .- ក.គ.ជ. ត្រូវកំណត់អំពីចំនួនទឹកប្រាក់វិភាគទានឯកភាពមួយដែលសមាជិកម្នាក់ៗត្រូវបង់នៅពេលសុំចុះឈ្មោះ និងត្រូវបង់ប្រចាំឆ្នាំ ។

ក.គ.ជ ត្រូវកំណត់ផងដែរនូវចំនួនវិភាគទានដែល ក.គ.ខ. ត្រូវបង់ជូនទៅ ក.គ.ជ. ទៅ ក.គ.ភ. និងត្រូវរក្សាទុកនៅក្នុង ក.គ.ខ. ដើម្បីធានាចំណាយក្នុងការបំពេញការងារជាទូទៅ ។ ការបង់វិភាគទានគឺជាកាតព្វកិច្ចរបស់សមាជិកម្នាក់ៗ ។ ក.គ.ជ គ្រប់គ្រងទ្រព្យសម្បត្តិទាំងអស់របស់គណៈគ្រូពេទ្យនឹងអាចបង្កើត ឬ ឧបត្ថម្ភដល់វណ្ណកម្មទាំងឡាយ ដែលជាផលប្រយោជន៍នៃវិជ្ជាជីវៈវេជ្ជសាស្ត្រ ព្រមទាំងការងារសង្គ្រោះផ្សេងៗ ។

ក.គ.ជ ត្រួតពិនិត្យការគ្រប់គ្រងរបស់ ក.គ.ខ. និង ក.គ.ភ. ។ ក.គ.ខ. ត្រូវរាយការណ៍ជូន ក.គ.ជ ជាមុន ចំពោះការបង្កើតអង្គការទាំងឡាយរបស់ខ្លួន ព្រមទាំងការចាត់ចែងរបស់អង្គការទាំងនោះ ។

**មាត្រា ៣៦** .- ក.គ.ជ. ត្រូវបង្កើតគណៈកម្មការមួយសំរាប់ត្រួតពិនិត្យគណនី និងការចាត់ចែងហិរញ្ញវត្ថុ ។

សមាជិកនៃគណៈកម្មការនេះ ត្រូវជ្រើសរើសដោយ ក.គ.ជ. ក្នុងចំណោមសមាជិកដែលមិនស្ថិតនៅក្នុងការិយាល័យនៃក្រុមប្រឹក្សា ។

ក្នុងដំណាច់ឆ្នាំនីមួយៗ គណៈកម្មការនេះត្រូវធ្វើរបាយការណ៍អំពីការត្រួតពិនិត្យរបស់ខ្លួនជូន ក.គ.ជ. ។

## ជំពូកទី ៣

## អវសានប្បញ្ញត្តិ

**មាត្រា ៣៧** .- នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣៨** .- ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០០០

ព្រះហស្ថលេខា

នរោត្តម សីហនុ

★★★